**សុន្ទរកថាបើក**

**កិច្ចប្រជុំបច្ចេកទេសប្រទេសបញ្ជូន**

**កម្ពុជា ឡាវ ភូមា**

**ដើម្បីការពារពលករទេសន្តរប្រវេសន៍ពីភាពរងគ្រោះដោយអំពើជួញដូរមនុស្ស**

ថ្ងៃទី ២៤២៥ ខែឧសភា ឆ្នាំ២០១៨

សៀមរាបអង្គរ ព្រះរាជាណាចក្រកម្ពុជា

សូមគោរពលោកជំទាវ **សាន្ត អារុណា** រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារ COMMIT កម្ពុជា និងឯកឧត្តម លោក លោកស្រី ក្នុងគណៈប្រតិភូអន្តរក្រសួង នៃព្រះរាជាណាចក្រកម្ពុជា

សូមគោរព លោក. Moving Keobounnavong, ប្រធាននាយកដ្ឋាន ជំនួយកុមារ អគ្គនាយកដ្ឋានសង្គមកិច្ច ក្រសួងការងារ និងសង្គមកិច្ច ។

លោកស្រី..... .................................លេខាធិការ និងជាទីប្រឹក្សាអមស្ថានទូតភូមា ប្រចាំនៅកម្ពុជា

លោក លោកស្រី ជាអង្គការដៃគូ និងសង្គមស៊ីវិល ទាំងអស់ជាទីរាប់អាន

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណ ចំពោះការអញ្ជើញចូលរួមរបស់គណៈប្រតិភូពីប្រទេសឡាវ និងប្រទេសភូមា ក៏ដូចជាលោកជំទាវ ឯកឧត្តម លោក លោកស្រី គណៈប្រតិភូប្រទេសកម្ពុជា ដែលជាមន្ត្រីបច្ចេកទេស ពីបណ្ដាក្រសួង និងអង្គភាពពាក់ព័ន្ធ អង្គការអន្តរជាតិ និងសង្គមស៊ីវិល ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ស្ដីពី «តួនាទីប្រទេសបញ្ជូន ក្នុងការការពារពលករទេសន្តរប្រវេសន៍ ពីអំពើជួញដូរមនុស្ស» ដែលកំពុងតែប្រារព្ធធ្វើ នៅក្នុងក្រុងសៀមរាប អង្គរ ខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា ។

ដូចលោកជំទាវ ឯកឧត្តម លោក លោកស្រី បានជ្រាបរួចមកហើយថា ប្រទេសយើងទាំងបី បាន និងកំពុងតែមានភាពប្រឈមដូចគ្នាលើបញ្ហាទេសន្តរប្រវេសន៍ ជាពិសេសនៅប្រទេសថៃ ។ ដូច្នេះ ក្នុងកិច្ចប្រជុំពីរថ្ងៃនេះ យើងនឹងពិភាក្សា ដោយបើកចំហរ ជាលក្ខណៈមិត្តភាព ដើម្បីរកឲ្យឃើញនូវបញ្ហាពិត និងត្រូវជ្រើសរើសអាទិភាពនៃបញ្ហា ដើម្បីបង្កើតគំនិតផ្ដួចផ្ដើមក្នុងការដោះស្រាយ ព្រមទាំងរៀនសូត្រពីគ្នាទៅវិញទៅមក នូវមេរៀនល្អៗ ដែលអាចអនុវត្តសម្រាប់ប្រទេសរៀងៗខ្លួន និងអាចជ្រើសរើសជាសកម្មភាពរួមសម្រាប់អនុវត្តក្នុងប្រទេសទាំងបី ។

គោលបំណងសិក្សាសំខាន់នៃកិច្ចប្រជុំនេះ គឺស្វែងយល់អំពីស្ថានភាព និងបទពិសោធន៍ល្អៗ ឬមេ

រៀនដែលទទួលបានក្នុងការបញ្ជូន និងគ្រប់គ្រងលំហូរមិនប្រក្រតីនៃទេសន្តរប្រវេសន៍ ដែលជាប្រភពនៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។ដើម្បីបូកសរុបការអនុវត្តល្អ មេរៀនដែលទទួលបាន ចំណុចខ្វះខាត និងបញ្ហាប្រឈមរួមនៃយន្តការការពារ និងក្របខ័ណ្ឌសម្រាប់ការពារសិទ្ធិពលករទេសន្តរប្រវេសន៍ ដែលប្រឈមនឹងហានិភ័យ រួមទាំងកុមារដែលជាអ្នកធ្វើទេសន្តរប្រវេសន៍ផងដែរ ពីការជួញដូរមនុស្ស ពលកម្មដោយបង្ខំ និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។

កំណត់រកយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាព ដើម្បីលើកជាអនុសាសន៍សំខាន់ៗដាក់ជូន និងស្វែងរកការគាំទ្រពីប្រមុខរដ្ឋាភិបាលនៃប្រទេសបញ្ជូនទាំងបី ដើម្បីពិភាក្សា និងធ្វើការតស៊ូមតិ ជាមួយនឹងប្រទេសគោលដៅ សំដៅរួមគ្នាលើកកម្ពស់សុវត្ថិភាពពលករទេសន្តរប្រវេសន៍ កាត់បន្ថយហានិភ័យដោយពលកម្មបង្ខំ អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មគ្រប់រូបភាព ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការដ៏ល្អ រវាងប្រទេសនានានៅក្នុងតំបន់ ដែលមានបញ្ហាប្រឈមប្រហាក់ប្រហែលគ្នា និងរកដំណោះស្រាយរួមគ្នាដើម្បីលើកកម្ពស់ការគោរពសិទ្ធិពលករ និងការគោរពឲ្យតម្លៃគ្នាទៅវិញទៅមក រវាងប្រទេសបញ្ជូននិងប្រទេសទទួល ។

កន្លងមក ពលករនៃប្រទេសទាំងបី កម្ពុជា ឡាវ ភូមា ត្រូវបានប្រទេសថៃ ដែលជាប្រទេសគោលដៅ ចាត់ចូលក្នុងប្រភេទមួយ ដែលមានកម្រិតទាបជាងពលករពីប្រទេសដទៃ (គឺជាកម្មករ និងជាអ្នកបម្រើ) ដែលគ្មានជំនាញ ឬមានជំនាញទាប ។ ពលករពីប្រទេសទាំងបី ទាំងពលករស្របច្បាប់ ទាំងពលករមិនមានឯកសារស្របច្បាប់ត្រូវបានទទួលយក និងប្រើប្រាស់នៅប្រទេសថៃ ដែលជាប្រទេសគោលដៅ ដែលធ្វើឲ្យការអនុវត្តអនុស្សរណៈ ស្តីពីការបញ្ជូន និងប្រើប្រាស់ពលករស្របច្បាប់ មិនមានប្រសិទ្ធភាព ។

ក្នុងនាមជាប្រទេសបញ្ជូន យើងមិនអាចគ្រប់គ្រងលំហូរនៃទេសន្តរប្រវេសន៍មិនប្រក្រតី ឆ្លងកាត់ព្រំដែន ដែលធ្វើឲ្យពលករជាច្រើនប្រឈមនឹងហានិភ័យ និងភាពរងគ្រោះដោយអំពើជួញដូរ និងការកេងប្រវ័ញ្ចគ្រប់រូបភាពបាន ហើយក៏មិនអាចប៉ាន់ប្រមាណពីផលប្រយោជន៍ និងផលប៉ះពាល់នៃទេសន្តរប្រវេសន៍បាន ដើម្បីមានវិធានការទប់ស្កាត់ឲ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលាបាន ព្រោះតែប្រទេសបញ្ជូន និងប្រទេសគោលដៅមានគោលនយោបាយមិនស៊ីសង្វាក់គ្នា ។

ប្រទេសនីមួយៗ មានរបៀបគ្រប់គ្រង បទដ្ឋាន និងនីតិវិធីក្នុងការអនុវត្តដោយឡែកៗពីគ្នា ហើយក៏មានទាំងចំណុចល្អ ទាំងចំណុចខ្វះខាត ។ ហេតុនេះ ការពិភាក្សា ដើម្បីរិះរកស្តង់ដាអនុវត្តមួយ ដែលសមស្របសម្រាប់ប្រទេសទាំងបី គឺជាការចាំបាច់សម្រាប់ការលើកកម្ពស់សុវត្ថិភាព និងផលប្រយោជន៍ពលករ ក៏ដូចជាកាត់បន្ថយភាពរងគ្រោះក្នុងអំឡុងពេលនៃទេសន្តរប្រវេសន៍ និងផលប៉ះពាល់អវិជ្ជមានចំពោះពលករ គ្រួសារ និងសង្គមជាតិយើង ។

ម្យ៉ាងទៀត ពលករមានតួនាទីនៃការអភិវឌ្ឍសេដ្ឋកិច្ច ហើយការបង្កើនប្រសិទ្ធភាពនៃអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ ត្រូវបានកំណត់យ៉ាងច្បាស់ថា ជាអាទិភាពមួយរបស់រដ្ឋជាសមាជិកអាស៊ាន ទើបមាន

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ត្រូវបានអនុម័ត ក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៧ ដោយរដ្ឋជាសមាជិកអាស៊ាន។ កិច្ចព្រមព្រៀងនេះ កំណត់យ៉ាងច្បាស់ពីកាតព្វកិច្ចរបស់រដ្ឋបញ្ជូនពលករ និងរដ្ឋទទួលពលករ (ក្នុងជំពូកទី ៥ និងជំពូកទី ៦) ដោយរដ្ឋសមាជិក ត្រូវបំពេញកាតព្វកិច្ចគោរព និងការពារសិទ្ធិពលករទេសន្តរប្រវេសន៍។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះសហគមន៍សេដ្ឋកិច្ចអាស៊ានពុំបានបញ្ចូលខ្លឹមសារស្តីពីការផ្លាស់ទីពលករគ្មានជំនាញ ពលករដែលមានជំនាញទាប និងពលករដែលមានជំនាញមធ្យម ក្នុងការឆ្លងព្រំដែនរបស់ប្រទេសនីមួយៗនោះឡើយ។ ដើម្បីសម្រេចឱ្យបាននូវសមធម៌ បរិយាបន្ន និងស្ថិរភាពនៃកំណើនអាស៊ាន ចាំបាច់ត្រូវមានរចនាសម្ព័ន្ធ ដែលឆ្លើយតបចំពោះលំហូរទេសន្តរប្រវេសន៍ទាំងនេះ។ នេះក៏ជាហេតុផលមួយ ដែលចាំបាច់ ប្រទេសយើង ក្នុងតួនាទីជាប្រទេសបញ្ជូនត្រូវពិភាក្សាគ្នា ដើម្បីរិះរកគំនិតផ្តួចផ្តើមសមស្រប សម្រាប់ដំណោះស្រាយទាំងនេះផងដែរ ។

ការកំណត់រកដំណោះស្រាយរួម ដែលសមស្រប ក៏នឹងត្រូវបានលើកយកទៅពិភាក្សាជាមួយប្រទេសថៃ ដែលជាប្រទេសគោលដៅ ដើម្បីរួមសហការគ្នា ការពារពលករ និងលើកកម្ពស់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (Safe, Orderly and Regular Migration) ទៅអនាគត ។

ខ្ញុំសង្ឃឹមថា កិច្ចពិភាក្សាបច្ចេកទេសរយៈពេលពីរថ្ងៃនេះ គឺជាការចាប់ផ្តើមមួយ ឆ្ពោះទៅរកដំណោះស្រាយរួម ដែលនឹងផ្តល់ផលប្រយោជន៍សម្រាប់ប្រទេសបញ្ជូន និងប្រទេសទទួល ក្នុងការបង្ហាញពីឆន្ទៈនយោបាយសម្រាប់កិច្ចការពារពលករពីភាពរងគ្រោះ ក្នុងអំឡុងពេលទេសន្តរប្រវេសន៍ ជាពិសេសពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ហើយនឹងផ្តល់ផលប្រយោជន៍ប្រកបដោយសមធម៌សម្រាប់ភាគីទាំងសងខាង គឺនិយោជក និងនិយោជិត និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ។

បន្ទាប់ពីកិច្ចប្រជុំនេះ យើងនឹងរៀបចំជារបាយការណ៍រួមមួយ (Minutes of the Meeting) ដែលត្រូវចុះហត្ថលេខារួមគ្នា ដោយដាក់ចេញនូវអនុសាសន៍ជាសំណើសំខាន់ៗ ចំពោះរដ្ឋាភិបាលនៃប្រទេសទាំងបី ក្នុងការផ្តួចផ្តើមជាដំណោះស្រាយរួមគ្នា និងសម្រាប់ការពិភាក្សាជាមួយប្រទេសថៃ ដែលជាប្រទេសគោលដៅ ដើម្បីលើកកម្ពស់ កិច្ចការពារពលករទេសន្តរប្រវេសន៍ឲ្យមានសុវត្ថិភាព និងទទួលបានផលប្រយោជន៍ដោយស្របច្បាប់ ព្រមទាំងការចែករំលែកប្រកបដោយសមធម៌ នូវការទទួលខុសត្រូវ លើការដោះស្រាយភាពប្រឈម និងផលប្រយោជន៍ រវាង និយោជក និងនិយោជិក និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ។

មិនតែប៉ុណ្ណោះ ការផ្តួចផ្តើមនេះ ក៏ជាការបំពេញករណីយកិច្ច របស់យើង ដែលជាប្រទេសសមាជិកក្នុងតំបន់ និងក្នុងពិភពលោកដែលបាន និងកំពុងតែយកចិត្តទុកដាក់ចំពោះ បញ្ហាទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្សផងដែរ ។

ជាថ្មីម្តងទៀត ក្នុងនាមគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្សកម្ពុជា សង្ឃឹមថា កិច្ចពិភាក្សានេះ នឹងទទួលបានលទ្ធផលជាផ្លែផ្កា ដែលប្រតិភូនីមួយៗ នឹងអាចយកទៅដាក់ជូនថ្នាក់ដឹកនាំទទួលបន្ទុក

ការងារប្រឆាំងការជួញដូរមនុស្ស និងការគ្រប់គ្រងទេសន្តរប្រវេសន៍ នៃប្រទេសរៀងខ្លួន ដើម្បីពិនិត្យ បំពេញបន្ថែម និងឈានទៅការជួបគ្នារវាងថ្នាក់ដឹកនាំប្រទេសទាំងបី ដើម្បីសម្រេចលើសេចក្ដីថ្លែងការណ៍រួម លើដំណោះស្រាយរួម នៅពេលអនាគតដ៏ខ្លីខាងមុខ និងអាចដាក់ស្នើការពិភាក្សា ជាមួយភាគីថៃ ក្នុងការរួមសហការគ្នា ដោះស្រាយបញ្ហាពលកររឲ្យបានរលូន ។

ខ្ញុំសូមបួងសួងដល់គុណព្រះរតនត្រ័យ បារមី វត្ថុសក្តិសិទ្ធ នៃទឹកដីមហានគរ ជួយបីបាច់ថែរក្សា លោកជំទាវ ឯកឧត្តម លោក លោកស្រី ទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ